**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

SOCIAL PROTECTION IN CAMBODIA

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

# សេចក្តីជូនដំណឹង
## ស្តីពី
## ការបើកផ្តល់ប្រាក់ឧបត្ថម្ភជូនបងប្អូនកម្មករនិយោជិតក្នុងវិស័យកាត់ដេរ និងទេសចរណ៍ ដែលត្រូវបានព្យួរកិច្ចសន្យាការងារស្របតាមស្មារតីនៃកញ្ចប់វិធានការរបស់រាជរដ្ឋាភិបាល (លើកទី៣៧)

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជូនដំណឹងដល់បងប្អូនកម្មករនិយោជិតចំនួន ៩ ០៥១ នាក់ នៃរោងចក្រ សហគ្រាស ទាំង៦៦ នៃវិស័យកាត់ដេរ និងវិស័យទេសចរណ៍ (ដូចមានភ្ជាប់នៅក្នុងឧបសម្ព័ន្ធ) ដែលទទួលបានការអនុញ្ញាតព្យួរកិច្ចសន្យាការងារស្របតាមស្មារតីជុំទី៣នៃកញ្ចប់វិធានការរបស់រាជរដ្ឋាភិបាលជ្រាបថា ធនាគារឯកទេសវីង នឹងផ្ញើសារអំពីការបើកប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាលទៅលេខទូរស័ព្ទ ដែលបងប្អូនបានផ្តល់មកឱ្យក្រសួងតាមរយៈរដ្ឋបាលរោងចក្រ សហគ្រាសនាពេលកន្លងមក។

ប្រាក់ឧបត្ថម្ភនេះនឹងត្រូវបើកផ្តល់ជាប្រាក់រៀល និងអាស្រ័យលើចំនួនថ្ងៃនៃការព្យួរកិច្ចសន្យាការងារ ក្នុងនោះចំនួន៖

- ៦០ ៧៥០រៀល (១៥ដុល្លារអាម៉េរិក) សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេល ៧ថ្ងៃ ដល់ ១០ថ្ងៃ
- ១២១ ៥០០រៀល (៣០ដុល្លារអាម៉េរិក) សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេល ១១ថ្ងៃ ដល់ ២០ថ្ងៃ
- ១៦២ ០០០រៀល (៤០ដុល្លារអាម៉េរិក) សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេលចាប់ពី ២១ថ្ងៃ ដល់ ១ខែ។ សូមបញ្ជាក់ថា សម្រាប់បងប្អូនដែលព្យួរកិច្ចសន្យាការងាររយៈពេល ២ខែ ប្រាក់ឧបត្ថម្ភនឹងត្រូវបើកជា ២លើក ដោយលើកទី២ នឹងបើកនៅថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២០។

ក្រសួងសូមរំឭកថា ធនាគារឯកទេសវីង នឹងបង្វិលប្រាក់ឧបត្ថម្ភនេះជូនរាជរដ្ឋាភិបាលវិញ ប្រសិនជាបងប្អូនខកខានមិនបានទៅបើកប្រាក់ឧបត្ថម្ភនេះ ក្នុងរយៈពេល ១០ថ្ងៃ បន្ទាប់ពីទទួលបានសារតាមទូរស័ព្ទពីធនាគារឯកទេសវីង។ ដើម្បីបើកប្រាក់ឧបត្ថម្ភនេះ បងប្អូនត្រូវយកអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ និងទូរស័ព្ទដែលទទួលបានសារនោះទៅកាន់ភ្នាក់ងារវីងដែលនៅជិតបំផុត។ សូមបញ្ជាក់ថា បងប្អូនមិនតម្រូវឱ្យបង់ថ្លៃសេវាទៅភ្នាក់ងារវីងឡើយពេលបើកប្រាក់ឧបត្ថម្ភនេះ។

ក្នុងករណីបងប្អូនកម្មករនិយោជិត ដែលបម្រើការងារនៅរោងចក្រ សហគ្រាស ទាំង៦៦ នេះ មិនបានទទួលសារទូរស័ព្ទពីធនាគារឯកទេសវីង នោះសូមបងប្អូនទំនាក់ទំនងសួរព័ត៌មានបន្ថែម ឬធ្វើបច្ចុប្បន្នភាពលេខទូរស័ព្ទរបស់ខ្លួន ទៅរដ្ឋបាលរោងចក្រ សហគ្រាសរបស់ខ្លួន។ ក្រសួងនឹងបន្តជូនដំណឹងដល់បងប្អូនកម្មកររោងចក្រ សហគ្រាសដទៃផ្សេងទៀតអំពីការបើកផ្តល់ប្រាក់ឧបត្ថម្ភនេះ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម សាធារណជន ជាពិសេសបងប្អូនកម្មករនិយោជិតជ្រាបជាព័ត៌មាន និងសូមរួសរាន់ទំនាក់ទំនងបើកប្រាក់ឧបត្ថម្ភនេះនៅតាមភ្នាក់ងារវីងនានាដែលនៅជិតបំផុតឱ្យបានទាន់ពេលវេលា។

*ថ្ងៃ សុក្រ ៥ កើត ខែ មិគសិរ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤*

*រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ២០២០*

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**គណៈកម្មការអនុវត្តវិធានការរាជរដ្ឋាភិបាល**

**ឧបសម្ព័ន្ធ នៃសេចក្តីជូនដំណឹងចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២០**

**បញ្ជីឈ្មោះ រោងចក្រ សហគ្រាស ក្នុងវិស័យកាត់ដេរ និងវិស័យទេសចរណ៍**
**ចំនួន ៦៦ ដែលទទួលបានប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាល**

| ល.រ | ឈ្មោះរោងចក្រ សហគ្រាស | រាជធានី ខេត្ត |
|---|---|---|
| ក. វិស័យកាត់ដេរ | | 18 |
| 1 | ក្រុមហ៊ុន ថេកអូហ្វ (ខេមបូឌា) | ភ្នំពេញ |
| 2 | ក្រុមហ៊ុន វ៉ាយ អេស ស៊ី យ៉ក់សាន់ស្ពារ(ខេមបូឌា)ឯ.ក | ភ្នំពេញ |
| 3 | ក្រុមហ៊ុន អ៊ីអឹមប៊ី ដែលកូរី (ខេមបូឌា) | ភ្នំពេញ |
| 4 | ក្រុមហ៊ុន ម៉ាសប្រាឌើរ ហ្គាម៉ិន មេនូហ្វេកឌឺរីង | ភ្នំពេញ |
| 5 | ក្រុមហ៊ុន ហាណា (ខេមបូឌា) អ៊ីង | ភ្នំពេញ |
| 6 | ក្រុមហ៊ុន មូនតៃ ខេជេ (ខេមបូឌា) ខូអិលធីឌី | កណ្ដាល |
| 7 | ក្រុមហ៊ុន វ៉ាន់កួន អ៊ិនដាសស្ទ្រៀល ខូ អិលធីឌី | កណ្ដាល |
| 8 | ក្រុមហ៊ុន ជីនវីន អ៊ីនដាសស្ទ្រី ខេមបូឌា ខូអិលធីឌី | កណ្ដាល |
| 9 | ក្រុមហ៊ុន មេរីខានអ៊ិនដាសស្ទ្រីហ្គាមេន(ខេមបូឌា)លីមីធីត | កណ្ដាល |
| 10 | ក្រុមហ៊ុន សាន់ហ្វ្រេស ស្ព័ត(ខេមបូឌា) ខូអិលធីឌី | កណ្ដាល |
| 11 | ក្រុមហ៊ុន លីវ តាន អ៊ីនធើណេសិនណល ខេមបូឌាខូអិលធីឌី | កំពង់ស្ពឺ |
| 12 | ក្រុមហ៊ុន សាប្រីណា (ខេមបូឌា) ហ្គាម៉ិន ម៉ែនញ៉ូហ្វាក់ធឺរីន ខប | កំពង់ស្ពឺ |
| 13 | ក្រុមហ៊ុន ហ្វ៊ូតហ្វ៊ររើត (ខេមបូឌា) សកខ៍ | កំពង់ស្ពឺ |
| 14 | ក្រុមហ៊ុន ថេនថេក អ៊ិនដាសស្ទ្រៀល ខូ អិលធីឌី | កំពង់ស្ពឺ |
| 15 | ក្រុមហ៊ុន ណាញ ស្កាយ ហ្គាម៉ិន ឯ.ក | តាកែវ |
| 16 | ក្រុមហ៊ុន តាគិសាដា(ខេមបូឌា) | ស្វាយរៀង |
| 17 | ក្រុមហ៊ុន យ៉កស៍(ខេមបូឌា) | ស្វាយរៀង |
| 18 | ក្រុមហ៊ុន អ៊ិម ដេ ប៉ែក (ខេមបូឌា) ខូអិលធីឌី | ព្រះសីហនុ |

| ល.រ | ឈ្មោះរោងចក្រ សហគ្រាស | រាជធានី ខេត្ត |
|---|---|---|
| ខ. វិស័យទេសចរណ៍ | | 48 |
| rrr | ក្រុមហ៊ុន តារាអ៊ែរផត | ភ្នំពេញ |
| 20 | ក្រុមហ៊ុន បាអាតហ្គត ឯ.ក | ភ្នំពេញ |
| 21 | ក្រុមហ៊ុន អិល&អិម បាសាក់ រីវើរ ខូ អិលធីឌី | ភ្នំពេញ |
| 22 | ក្រុមហ៊ុន អលមិន ខូ អិលធីឌី | ភ្នំពេញ |
| 23 | ក្រុមហ៊ុន ហ្វូដឡាយហ្វ៍ ឯ.ក | ភ្នំពេញ |
| 24 | សណ្ឋាគារ រ៉េស៊ីដង់ សុខាភ្នំពេញ | ភ្នំពេញ |
| 25 | ក្រុមហ៊ុន យូ្យ យូ្យ ត្រាវែល អេជេនស៊ី | ភ្នំពេញ |
| 26 | ក្រុមហ៊ុន អេមខេត (ខេមបូឌា) ឯ.ក | ភ្នំពេញ |
| 27 | សណ្ឋាគារ អូឡាំព្យា ស៊ីធី ហូថេល | ភ្នំពេញ |
| 28 | ក្រុមហ៊ុន វើលដ៏អិចប្រេស | ភ្នំពេញ |
| 29 | ក្រុមហ៊ុន ថាលាស | ភ្នំពេញ |
| 30 | ក្រុមហ៊ុន អេឃ្សើ អេកស្ពីឌីសិន (ខេមបូឌា) ខូ អិលធីឌី | ភ្នំពេញ |
| 31 | ក្រុមហ៊ុន វីណា ហុងកុង ខំផែនី អែលធីឌី | ភ្នំពេញ |
| 32 | ក្រុមហ៊ុន ឌីថាមត្រាវែល ខេមបូឌា | ភ្នំពេញ |
| 33 | សណ្ឋាគារ សុខាល័យអង្គរ រីហ្សត និងស្ប៉ា | សៀមរាប |
| 34 | ក្រុមហ៊ុន កូបេ យៃភែននីស រែស្តូរែន | សៀមរាប |
| 35 | ក្រុមហ៊ុន អេច ឌី រ៉ក កាហ្វេ & សប | សៀមរាប |
| 36 | ក្រុមហ៊ុន ជាតិថាតា អង្គរ | សៀមរាប |
| 37 | សណ្ឋាគារ តារា អង្គរ | សៀមរាប |
| 38 | ក្រុមហ៊ុន រ៉ូយ៉ាល់អង្គរ (សណ្ឋាគារសូហ្វីតែលអង្គរភូគីត្រាហ្គោហ្វ & ស្ប៉ារីហ្សត) | សៀមរាប |
| 39 | សណ្ឋាគារខេមរាអង្គរ | សៀមរាប |
| 40 | សណ្ឋាគារ ដឹឡាពេ (ផាកហៃយ៉ាត់សៀមរាប) | សៀមរាប |
| 41 | សណ្ឋាគារ អូរៀនថល ជេ7 | សៀមរាប |
| 42 | សណ្ឋាគារ យីងដុម អង្គរ | សៀមរាប |
| 43 | ក្រុមហ៊ុន អេមព្រីស អង្គរ | សៀមរាប |
| 44 | ក្រុមហ៊ុន ចាយ៉ាហៅស៍រីវើរផាក សៀមរាប ឯ.ក | សៀមរាប |
| 45 | សណ្ឋាគារ ស្មាយលីង | សៀមរាប |
| 46 | សណ្ឋាគារ វិរតន៍ | សៀមរាប |

| ល.រ | ឈ្មោះរោងចក្រ សហគ្រាស | រាជធានី ខេត្ត |
|---|---|---|
| 47 | ក្រុមហ៊ុន ញូវ រីវើរ សាយ | សៀមរាប |
| 48 | ផ្ទះសំណាក់ ហនុមានាល័យ | សៀមរាប |
| 49 | ក្រុមហ៊ុន វិរតន៍ វីឡា | សៀមរាប |
| 50 | សណ្ឋាគារតាព្រហ្ម | សៀមរាប |
| 51 | ក្រុមហ៊ុន អង្គរ សេនជូរី គ្រុប ភីធីអ៊ី អែលធីឌី | សៀមរាប |
| 52 | ភោជនីយដ្ឋាន វិរតន៍ | សៀមរាប |
| 53 | សណ្ឋាគារ សាឯមសៀមរាប | សៀមរាប |
| 54 | ក្រុមហ៊ុន បាហ្វឹឡូធួរ (ខេមបូឌា) លីមីតធីត | សៀមរាប |
| 55 | ក្រុមហ៊ុន ណាវូទូ ឌ្រីម | សៀមរាប |
| 56 | ក្រុមហ៊ុន ស៊ីវ៉ាយ-អេសអ ហូថេល ហ្វ្រេន ឡាយអិន ឯ.ក | សៀមរាប |
| 57 | សណ្ឋាគារ លីនាយាអង្គរ រីសត និងស្ប៉ា | សៀមរាប |
| 58 | ក្រុមហ៊ុន អង្គរ ប៉ាណូរ៉ាមីក ប៊ូទិក ឯ.ក | សៀមរាប |
| 59 | ក្រុមហ៊ុន អឹបៅអេស៊ា | សៀមរាប |
| 60 | សណ្ឋាគារម៉េម័រសៀមរាប | សៀមរាប |
| 61 | ក្រុមហ៊ុន ម៉េម័រ អង្គរ | សៀមរាប |
| 62 | សណ្ឋាគារ សារ៉ៃរីសត និង ស្ប៉ា | សៀមរាប |
| 63 | សណ្ឋាគារ អង្គរ | សៀមរាប |
| 64 | សណ្ឋាគារសុខាសៀមរាប | សៀមរាប |
| 65 | សណ្ឋាគារ សុខាអង្គរ | សៀមរាប |
| 66 | ក្រុមហ៊ុន រមណីយដ្ឋានឆ្នេរសុខា | ព្រះសីហនុ |